# រុក្ខជាតិ និងអ្នកថែរក្សានៅក្នុងសង្គមខ្មែរសម័យបុរាណ

មិនថាតែនៅសម័យបច្ចុប្បន្ននោះទេ ដែលរុក្ខជាតិមានសារៈសំខាន់យ៉ាងខ្លាំងសម្រាប់ការរស់នៅរបស់មនុស្ស រីឯនៅសម័យបុរាណរុក្ខជាតិក៏សំខាន់ដូចគ្នា។ រុក្ខជាតិ និងបរិស្ថានធម្មជាតិ គឺជាប្រភពមិនចេះរីងស្ងួត ឬអាចនិយាយបានថា ជាប្រភពនៃជីវិតមនុស្ស សត្វ និងជាធាតុផ្សំដ៏សំខាន់មួយរបស់វប្បធម៌ផងដែរ។ នៅក្នុងសិលាចារឹកបុរាណខ្មែរ រុក្ខជាតិបានដើរតួនាទី និងផ្សារភ្ជាប់យ៉ាងសំខាន់នៅក្នុងសង្គមមនុស្ស ទាំងការប្រើប្រាស់ប្រចាំថ្ងៃ និងការប្រណិប័តន៍ប្រព័ន្ធជំនឿ។ ក្រៅពីនោះ យើងសង្កេតឃើញថា នៅសម័យបុរាណហាក់ដូចជាមានប្រព័ន្ធគ្រប់គ្រងរុក្ខជាតិ ឬព្រៃឈើយ៉ាងជាក់លាក់មួយដូចសម័យបច្ចុប្បន្នមានក្រសួងបរិស្ថានជាអ្នកគ្រប់គ្រងដូច្នោះដែរ។ នៅក្នុងអត្ថបទខ្លីនេះ យើងនឹងបង្ហាញកស្តុតាងខ្លះៗអំពីតួនាទី ការប្រើប្រាស់ និងការគ្រប់គ្រងព្រៃឈើ ឬរុក្ខជាតិនៅសម័យបុរាណ ដោយយោងទៅលើព័ត៌មានសិលាចារឹកបុរាណខ្មែរ។

## ១. ស្ថាននាមបុរាណទាក់នឹងរុក្ខជាតិ

ចាប់តាំងពីសតវត្សរ៍ទី៧មក សិលាចារឹកខ្មែរបុរាណបានបង្ហាញទីកន្លែងជាច្រើនដែលមានឈ្មោះជាប់ពាក់ព័ន្ធនឹងរុក្ខជាតិ (រូបលេខ១)។ ឧទាហរណ៍ ឈ្មោះខេត្តដែលទាក់ទងនឹងរុក្ខជាតិមានដូចជា ប្រមាណជ្រៃនន្ទ (K.393) ប្រមាណព្រៃស្វាយ (K.989) ប្រមាណព្រៃរមៀត (K.380) ប្រមាណដើមខ្យល់ (K.944) ប្រមាណ សន្ទុក (K.756)។ រីឯឈ្មោះស្រុកនៅសម័យបុរាណដែលយករុក្ខជាតិមកសម្គាល់ជាឈ្មោះមានដូចជា ស្រុកស្តុកឫស្សី (K.219) ស្រុកព្រៃត្របែក (K.720) ស្រុកព្រៃដើមថ្នឹង (K.105) ស្រុកចំបក់ (K.344) ស្រុកជ្រៃរៀន (K.178) ស្រុកព្រៃត្បែង (K.292) ស្រុកព្រះផ្ទឹក (K.292) ស្រុកសំពោង (K.713) ស្រុកដើមថ្ងាន់ (K.292) ស្រុកដើមស្វាយ (K.292) ស្រុកសង្កែ (K.67) ស្រុកដូងមួយដើម (K.235) ស្រុកត្រពាំងកន្ទួត (K.820) ស្រុកឃ្នួញ (K.235)។[១] ក្រៅពីនេះមានស្ថាននាមជាច្រើនទៀតដែលមានឈ្មោះទាក់ទងនឹងរុក្ខជាតិ មិនត្រឹមតែប្រមាណ និងស្រុកទេ ពោល គឺមានទាំងឈ្មោះភូមិ (ដី) ឈ្មោះស្ទឹង ឈ្មោះទន្លេ ឈ្មោះបឹង ឈ្មោះស្តុក ឈ្មោះចង្អូរ ឈ្មោះព្រៃ ។ល។

## ២. ឱសថទាក់នឹងរុក្ខជាតិ

នៅរវាងចុងស.វ.ទី១២ ដើមស.វ.ទី១៣ គេដឹងថាវិស័យសុខាភិបាលទំនងជាមានការរីកលូតលាស់គួរកត់សម្គាល់ ដ្បិតសិលាចារឹកនៅប្រាសាទតាព្រហ្មបានឱ្យដឹងថា យ៉ាងហោចណាស់

[១] កំ វណ្ណាវ៉ា ២០២០។

អត្ថបទដោយ៖ កំ វណ្ណាវ៉ា

មានមន្ទីរពេទ្យចំនួន ១០២ នៅទូទាំងប្រទេស ក្នុងរជ្ជកាលព្រះបាទជ័យវរ្ម័នទី៧ (គ.ស.១១៨១ ដល់ ១២២០)។ ក្នុងនោះ គេដឹងបន្ថែមថា សិលាចារឹកដែលចារឹកនៅតាមហោរបន់ស្រន់មន្ទីរភាគច្រើន សរសេរជាភាសាសំស្រ្កឹត ហើយមានខ្លឹមសារស្ទើរតែដូចគ្នាទាំងស្រុង។ អ្វីដែលគួរកត់សម្គាល់នោះ គឺសិលាចារឹកទាំងនោះរៀបរាប់ឱ្យដឹងថា គេបានយករុក្ខជាតិមកប្រើប្រាស់ជាឱសថសម្រាប់ព្យាបាលអ្នកជំងឺថែមទៀតផង។ ឧទាហរណ៍ សិលាចារឹកព្រះធាតុរកា ខេត្តកំពង់ធំ K.435[២] ស្លោកទី៣២ រៀបរាប់ថា (រូបលេខ១២)៖

ហិង្គុក្សារំ តោត្តដិណំ  មេកោកាញ្ចកចាងកាមិ
បញ្ចវិមវន្តុកប្ប៉ំ  កក្កោរាយាះ បលទ្វយមិ។

*ប្រែសម្រួលថា៖*

*ហិង្គុ អំបិល ផ្លែក្រវ៉ាន់តូច និងផ្លែកំញាននីមួយៗទំងន់មួយបាទ កប្បូរចំនួន៥ ទឹកត្នោត២បលៈ។*

## ៣. ជំនឿទាក់ទងនឹងរុក្ខជាតិ

យោងតាមសិលាចារឹកប្រាសាទភិមានអាកាស K.834[៣] បញ្ជាក់ថា គេបានចាត់ទុកដើមពោធិព្រឹក្សស្មើនឹងទេពនៅក្នុងព្រហ្មញ្ញសាសនា ដោយឫសដើមពោធិតំណាងឱ្យព្រះព្រហ្ម តួដើមពោធិតំណាងឱ្យព្រះឥសូរ និងមែកដើមពោធិតំណាងឱ្យព្រះវិស្ណុ។ បន្ថែមពីនេះ គេបានហាមប្រាមមិនឱ្យនរណាបំផ្លាញដើមពោធិនេះបានឡើយ សូម្បីតែស្តេចផែនដី ភ្លើង ដែក ដឹង ដំរី ខ្យល់ រន្ទះ ក៏មិនអាចមកបៀតបៀនបានឡើយ (រូបលេខ១៣)។

ឧទាហរណ៍ខ្ញុំខាងលើបញ្ជាក់ថា នៅសម័យបុរាណ ក៏មិនខុសពីសម័យទំនើបនេះដែរពោល គឺគេតែងតែយករុក្ខជាតិផ្សំធ្វើជាឱសថសម្រាប់ព្យាបាលជំងឺមកទល់សព្វថ្ងៃ។

## ៤. អ្នកថែរក្សារុក្ខជាតិ ឬព្រៃឈើ

នៅសម័យបច្ចុប្បន្ន មន្ត្រីរាជការដែលមានតួនាទីការពារព្រៃឈើ ឬបរិស្ថានធម្មជាតិ គេច្រើនប្រើពាក្យថា “**ឧទ្យានរក្ស**” ស្ថិតនៅក្រោមឱវាទក្រសួងបរិស្ថាន។ នៅសម័យបុរាណខ្មែរ យើងឃើញថា រាជការបានតែងតាំងមនុស្សជា “**ក្លោញ ឈេ វ្រៃយ៍**” ដែលត្រូវនឹងសំណេរទំនើបថា “**ខ្លោញ ឈើព្រៃ**” ប្រែសម្រួលមកថា “ប្រធានខាងព្រៃឈើ”។ ពាក្យនេះបើគិតមកបច្ចុប្បន្ន វាត្រូវនឹងពាក្យគេហៅក្រៅជាទូទៅថា “**មេព្រៃ**” ដែលជាផ្លូវការជាមន្ត្រីនៅក្នុង “**រដ្ឋបាលព្រៃឈើ**”។

---

[២] Finot 1915.

[៣] Coedès 1989.

អត្ថបទដោយ៖ កំ វណ្ណារ៉ា

ពាក្យ "**ក្ញោញ ឈេ ព្រៃយ៑**" លេចឡើងនៅក្នុងសិលាចារឹកមួយ (មិនស្គាល់ប្រភពទីតាំងរកឃើញ) នៅខេត្តតាកែវ ចុះបញ្ជីលេខ K.79 ចារឹកជាភាសាខ្មែរបុរាណ នៅគ.ស.៦៣៩ ក្នុងរជ្ជកាលព្រះបាទភវវរ្ម័នទី២ (រូបលេខ៤)។ ខ្លឹមសារដើមរបស់សិលាចារឹកនេះរៀបរាប់ថា៖ *"ក្ញោញ៑ឈេព្រៃ យ៑ឱ្យ៑គិនោះស្រេសោត៑តវ្រះក្ញោញ៑ទារណិកចន្ទក្តទ្រោង៑បោញ៑គិរចន្រ្ទកោន៑ក្ញោញ៑អំវល៑យោ១ វ្រះ១ត្នុផើម៑១ស្រូ ត្ឡោង៑៣"* ប្រែសម្រួលថា "**ក្ញោញឈើព្រៃ (មេព្រៃ ឬរដ្ឋបាលព្រៃឈើ) បានបរិច្ចាកស្រែថ្វាយដល់ព្រះក្ញោញ បានទទួលដោយ ណិកចន្ទក្ត ព្រមទាំងបោញសិរចន្រ្ទ កូន ក្ញោញអំវល ១យៅ ១ វ្រះ គោផើម១ ស្រូវ ៣ ត្លោង**"។[៤]

ជាសេចក្តីសន្និដ្ឋានរួមមក យើងឃើញថា រុក្ខជាតិពិតជាដើរតួនាទីយ៉ាងសំខាន់សម្រាប់ការរស់នៅរបស់មនុស្សនៅសម័យបុរាណ។ ក្នុងនោះ ស្ថាននាមជាច្រើនសម្គាល់ដោយរុក្ខជាតិដូចមានរៀបរាប់នៅក្នុងសិលាចារឹកយ៉ាងសន្ធឹកសន្ធាប់។ ក្រៅពីនេះ ក៏មានសិលាចារឹកមួយចំនួនបានផ្តល់ភស្តុតាងអំពីជំនឿ និងការប្រើប្រាស់ឱសថទាក់ទងជាមួយរុក្ខជាតិ។ អ្វីដែលពិសេសនោះគឺសិលាចារឹកមកពីខេត្តតាកែវ បានផ្តល់ព័ត៌មានឱ្យដឹងពីការគ្រប់គ្រងព្រៃឈើនៅសម័យបុរាណ។ យើងពុំដឹងអំពីឋានៈនុក្រមមន្រ្តីរាជការទាក់ទងនឹងព្រៃឈើនេះច្បាស់ទេ ប៉ុន្តែភស្តុតាងដ៏តូចនេះស្តែងឱ្យឃើញអំពីការយកចិត្តទុកដាក់នៅសម័យបុរាណក្នុងការថែរក្សាការពារព្រៃឈើដូចនៅសម័យថ្មីយើងដែរ។

## ឯកសារយោង


**កំ វណ្ណាក់**

២០២០, *កម្ពុជស្ថាននាម សម័យអង្គរ ស.វ.ទី៩-១៤*, ភ្នំពេញ។

**Coedès, G.**

1950, *Inscription du Cambodge*, Vol II, Hanoi.

1989, *Articles sur le pays Khmer,* Tome I, published by EFEO, Paris.

**Finot, L.**

1915, Notes d’epigrahie, les inscription du musée de Hanoi, *BEFEO*, Tome 15, pp. 1-135.


[៤] Coedès 1950.



រូបលេខ១៖ សិលាចារឹកប្រាសាទព្រះគោ K. 713 (ផ្តិតដោយ៖ កំ វណ្ណាក់)

អត្ថបទដោយ៖ កំ វណ្ណាក់



រូបលេខ១២៖ សិលាចារឹកគោករកា K.435 មុខ "គ" (ប្រភព៖ sealang.net)

អត្ថបទដោយ៖ កំ វណ្ណារ៉ា



រូបលេខ៣៖ ក្រដាសផ្ដិតសិលាចារឹកភិមានអាកាស K.484 (ផ្ដិតដោយ៖ កំ វណ្ណារ៉ា )

អត្ថបទដោយ៖ កំ វណ្ណារ៉ា



រូបលេខ៤៖ ក្រដាសផ្ដាមសិលាចារឹកមកពីតាកែវ ដែលមានពាក្យ "ក្មោញឈេវ្រៃយ" (ក្មោញឈើព្រៃ)
(ប្រភព៖ សារមន្ទីរជាតិភ្នំពេញ)

អត្ថបទដោយ៖ កំ វណ្ណារ៉ា